

# ការមានផ្ទៃពោះ និង ខ្ញុំ

## ស្ត្រីនិងមេរោគ HIV: ក្រដាស់ពត៌មានបន្តបន្ទាប់គ្នា សំរាប់ស្ត្រី ស្តីអំពីមេរោគ HIV



ការធ្វើតេស្តរកមើលមេរោគ HIV



ការទើបតែបានរកឃើញមានមេរោគថ្មីៗ



ការព្យាបាលផ្សេងៗ: កត្តាសំខាន់ ។



ការមើលថែទាំខ្លួនអ្នក



កិច្ចបំរើផ្សេងៗ រដ្ឋ NSW និង គេហទំព័រ

### កំពុងគិតចង់មានទារកឬ?

មេរោគ HIV មិនអាចរារាំងនូវបំណង ឬសិទ្ធិលោក អ្នកពីការមានទារកឡើយ។ នេះបណ្តលមកពី គេប្រើវិធីទំនើបក្នុងការព្យបាលមេរោគ HIV។ គ្រោះថ្នាក់ពីការឆ្លងមេរោគ HIV ដល់ទារកគឺ មានកំរិតទាបជាទីបំផុត ។

### គំរោងការមានផ្ទៃពោះ

ប្រសិនបើលោកអ្នក កំពុងគិតចង់បានទារក ចូរពិភាក្សាជាមួយវេជ្ជបណ្ឌិតអំពីបញ្ហានេះ។ វេជ្ជបណ្ឌិតលោកអ្នកនឹងអាចអោយដំបូន្មានអំពី:

- ពេលវេលាដែលល្អបំផុត សំរាប់ការមានផ្ទៃពោះ (រួមទាំងការទាក់ទងមេរោគ HIV និងដំណើរការនៃការមករដូវរបស់អ្នក)
- ជំរើសដែលមានសុវត្ថិភាព សំរាប់ដៃគូ បើសិនជាគាត់មានមេរោគ HIV អវិជ្ជមាន (ដូចជាការចាក់ បញ្ចូលមេជីវិតដោយខ្លួនឯង)
- របៀបកាត់បន្ថយនូវគ្រោះថ្នាក់ ឆ្លងHIV ទៅទារក
- ការការព្យបាលមេរោគ HIV ល្អបំផុតសំរាប់អ្នកនិងទារក (ថ្នាំព្យាបាលមេរោគ HIV មួយចំនួនមិនមានសុវត្ថិភាពក្នុងការប្រើនៅពេលកំពុងមានផ្ទៃពោះទេ)។

ប្រសិនលោកអ្នកមានដៃគូទៀងទាត់គឺជាការ ប្រសើរដែលអ្នកទាំងពីរជជែកគ្នា អំពីជំរើសហើយធ្វើការសំរេចចិត្តដែលស្រួលដល់ អ្នកទាំងអស់គ្នា។

### ការមានផ្ទៃពោះដោយឥតគ្រោងទុក

ប្រសិនបើលោកអ្នក មានផ្ទៃពោះដោយឥតគ្រោងទុក ឬ ត្រូវបានគេរកឃើញនូវមេរោគ HIV នៅពេលកំពុង មានផ្ទៃពោះ គឺជាការសំខាន់ដែលលោកអ្នកពិភាក្សា ជាមួយវេជ្ជបណ្ឌិត អោយឆាប់ដែលអាចធ្វើទៅបាន។ មានជំរើសជាច្រើន ដើម្បីការពារកុំអោយឆ្លងមេរោគ HIV ទៅទារកនៅគ្រប់ដំណាក់កាលនៃការមានផ្ទៃពោះ។ លោកអ្នកធ្វើយ៉ាងណាអោយយល់ពីឱវាទមុននឹងធ្វើការសំរេច ចិត្ត។ លោកអ្នកអាចនាំដៃគូមិត្តភក្តិ ឬបុគ្គលិកធ្វើការផ្នែកជួយគាំទ្រ ពេលទៅជួបជាមួយវេជ្ជបណ្ឌិត។

### ការជួយកាត់បន្ថយនូវគ្រោះថ្នាក់ចម្លងមេរោគ HIV ទៅទារក

មានបួនដំណាក់កាល ដែលគេបានដាក់អោយអនុវត្តន៏:

- ការព្យាបាលមេរោគ HIV ពេលកំពុងមានផ្ទៃពោះ
- កុំបំបៅកូនដោយទឹកដោះម្តាយ
- អោយថ្នាំ HIV ទៅទារក
- គួរតែប្រើវីធីវះកាត់ នៅពេលសំរាលកូនមានការព្យាបាលតាមកំរិតត្រឹមត្រូវនិងមានសុវត្ថិភាពសំរាប់អ្នកមានផ្ទៃពោះ។ វេជ្ជបណ្ឌិតនឹងពិភាក្សានូវដំណាក់កាលទាំងនេះ ជាមួយលោកអ្នក ។

### ថ្នាំសំរាប់ទារកទើបនឹងកើត

ទារករបស់លោកអ្នកនឹងត្រូវគេផ្តល់ថ្នាំ HIV អោយចាប់ពីកើតដល់ប្រាំមួយសប្តាហ៏។ ថ្នាំទាំងនេះមានទំរង់ជាទឹកស៊ីរ៉ូប។ វេជ្ជបណ្ឌិតនឹងប្រាប់លោកអ្នក បើសិនជា ទារកត្រូវការថ្នាំបន្ថែមផ្សេងៗទៀត។

### តើពេលណាខ្ញុំនឹងអាចដឹងថា កូនខ្ញុំមានមេរោគ HIV វិជ្ជមាន ឬអវិជ្ជមាន?

កូនលោកអ្នកនឹងត្រូវគេធ្វើតេស្តទៀងទាត់ ដើម្បីរកមេរោគក្នុងរយះពេលប្រាំមួយខែដំបូង។
គេចាត់ទុកថាទារកមិនមានមេរោគ HIV ទេនៅពេលទារកបានអាយុបីខែ បើសិនជាការធ្វើតេស្តទាំងអស់អវិជ្ជមានហើយទារកមិនបៅដោះម្តាយ។ ការធ្វើតេស្ត ត្រូវគេបន្តរហូតដល់ទារកអាយុ១៨ខែដើម្បី បញ្ជាក់ ថាទារកគ្មានមេរោគទៀតទេ។

FAMILY PLANNING NSW
www.fpnsw.org.au

acon
BUILDING OUR COMMUNITY'S HEALTH & WELLBEING

Multicultural HIV/AIDS and Hepatitis C Service

HIV + HETEROSEXUALS

ពត៌មាននេះធ្វើឡើងដោយ FPNSW និងការចូលរួមពី MHAHS, ACON និង HHAS នាខែមិថុនា 2009

## មន្ទីរពេទ្យ

មន្ទីរពេទ្យទាំងអស់ក្នុងរដ្ឋ NSW ត្រូវតែមានពត៌មាន ថ្មីៗអំពីការថែទាំពេលម្តាយកំពុងមានផ្ទៃពោះ និងពេលសំរាលកូនសំរាប់ស្ត្រីដែលមានមេរោគ HIV។ ទោះជាយ៉ាងនេះក្តី បទពិសោធន៍អាចខុសៗគ្នាទៅតាមមន្ទីរពេទ្យនិមួយៗ។

មន្ទីរពេទ្យ Royal សំរាប់ស្ត្រី និងមន្ទីរពេទ្យកុមារនៅ Sydney មានបទពិសោធន៍ជាច្រើន ផ្នែកការ ថែទាំពេលម្តាយកំពុងមានផ្ទៃពោះ និងពេលសំរាលកូនក្នុងរដ្ឋ NSW។ លោកអ្នកអាចពិគ្រោះយកដំបូលមានពីមន្ទីរពេទ្យទាំងនេះ ដើម្បីស្វែងរកកិច្ចបំរើក្នុងតំបន់ លោកអ្នក។ ពួកគេអាចជួយគាំទ្រនិងជួយផ្តល់ពត៌មានដោយ មិនគិតអំពីការជ្រើសរើសយកទីកន្លែងសំរាលកូន របស់លោកអ្នកទេ។

## ការជួយគាំទ្រ

ការមានផ្ទៃពោះ និងភាពជាម្តាយ អាចជាពេលវេលាដ៏លំបាក តែទន្ទឹមនឹងនេះក៏ជាការសប្បាយរីករាយក្នុង ឆាកជីវិតដែរ។

មានមនុស្សមួយក្រុមដែលអាចជួយយើងបាន គឺអាចធ្វើអោយអ្វីៗងាយស្រួលឡើងបន្តិច ដែរ។ និយាយទៅកាន់មិត្តភក្តិ ក្រុមគ្រួសារ ឬ បុគ្គលិក ជួយគាំទ្រ ដើម្បីស្វែងរកថា តើគេអាចជួយ អ្វីដល់អ្នកខ្លះ។ លោកអ្នកក៏ប្រហែលជាចង់និយាយទៅកាន់ស្ត្រីដែលមាន មេរោគ HIV ដទៃទៀតអំពីការបទពិសោធន៍របស់គេ។

## កិច្ចបំរើផ្សេងៗ

លោកអ្នកក៏អាចរកមើលកិច្ចបំរើរដ្ឋ NSW និងតាមគេហទំព័រក្រដាសពត៌មាន

The Heterosexual HIV/AIDS Service (Pozhet)
ទូរស័ព្ទដោយឥតគិតថ្លៃ: 1800 812 404

ACON Women & Families Affected by HIV Project
ទូរស័ព្ទ : (02) 9699 8756

កិច្ចបំរើពហុវប្បធម៌ HIV/AIDS និងជំងឺរលាកថ្លើម ប្រភេទ ជ
ទូរស័ព្ទ: (02) 9515 5030

កិច្ចបំរើ HIV សំរាប់កុមារ នៃមន្ទីរពេទ្យកុមារនៅ Sydney
ទូរស័ព្ទ: (02) 9382 1851

**ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែ សូមទូរស័ព្ទលេខ:** 131 450

សំរាប់ការអានបន្ថែម: សូមបើកគេហទំព័រខាងក្រោម ឬ សួររកឯកសារ ពីបុគ្គលិកជួយគាំទ្រ

មានមេរោគពេលមានផ្ទៃពោះ (Positive pregnancy)
មន្ទីរពេទ្យកុមារ Sydney (Sydney Children's Hospital )
http://www.sch.edu.au/departments/hiv/positive_pregnancy_booklet.pdf

ការមើលថែទាំខ្លួនអោយបានត្រឹមត្រូវ (Treat yourself right)
http://www.afao.org.au/library_docs/resources/TYR_07.pdf

## ការមានផ្ទៃពោះ និង ខ្ញុំ



ស្ត្រីនិងមេរោគ HIV: ក្រដាស់ពត៌មានបន្តបន្ទាប់គ្នា សំរាប់ស្ត្រី ស្តីអំពីមេរោគ HIV

ពត៌មាននេះធ្វើឡើងដោយ FPNSW និងការចូលរួមពី MHAHS, ACON និង HHAS នាខែមិថុនា 2009